គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
អគ្គលេខាធិការដ្ឋាន

លេខ: ០៧៣ គ.ជ.ប.អគ្គ

ថ្ងៃ ច័ន្ទ ១៣ កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែមិថុនា ឆ្នាំ២០២៣

# សេចក្តីប្រកាសព័ត៌មាន

## គ.ជ.ប បានប្រជុំផ្សព្វផ្សាយអំពីគោលការណ៍នៃការរៀបចំកម្មវិធីសំណួរចម្លើយ ឬពិភាក្សា និងការជួលម៉ោងផ្សាយពីគោលនយោបាយរបស់គណបក្សនយោបាយ ជាមួយតំណាងស្ថានីយវិទ្យុ និងទូរទស្សន៍ និងសមាគម អង្គការមិនមែនរដ្ឋាភិបាល

នាព្រឹកថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៣ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានជួបប្រជុំជាមួយតំណាងស្ថានីយវិទ្យុ និងទូរទស្សន៍ តំណាងសមាគម និងអង្គការមិនមែនរដ្ឋាភិបាល នៅទីស្តីការ គ.ជ.ប ក្រោមអធិបតីភាពឯកឧត្តម **ម៉ុក ដារ៉ា** អគ្គលេខាធិការរង គ.ជ.ប និងជាប្រធានគណៈកម្មការសម្របសម្រួលកម្មវិធីផ្សព្វផ្សាយអប់រំអ្នកបោះឆ្នោត និងកម្មវិធីផ្សព្វផ្សាយគោលនយោបាយរបស់គណបក្សនយោបាយ ហៅកាត់ថា "គណៈកម្មការសម្របសម្រួល" ដើម្បីផ្សព្វផ្សាយអំពី៖

- គោលការណ៍សម្រាប់ស្ថានីយវិទ្យុ និងទូរទស្សន៍ ក្នុងការលក់ ឬជួលម៉ោងផ្សព្វផ្សាយឱ្យគណបក្សនយោបាយ ដើម្បីធ្វើការផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់ខ្លួនក្នុងអំឡុងពេលឃោសនាបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣
- គោលការណ៍សម្រាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ស្តីពីការរៀបចំកម្មវិធីសំណួរចម្លើយ ឬពិភាក្សាអំពីគោលនយោបាយរបស់គណបក្សនយោបាយក្នុងអំឡុងពេលឃោសនាបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣។

គោលការណ៍ខាងលើនេះ មាន ២ ច្បាប់ផ្សេងគ្នា ហើយត្រូវបានចែកជូនតំណាងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរដ្ឋ និងឯកជន និងសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលចូលរួមក្នុងកិច្ចប្រជុំនេះ និងមានបង្ហោះផ្សាយនៅលើគេហទំព័រ គ.ជ.ប www.nec.gov.kh ។

នាឱកាសនោះ ឯកឧត្តម **ម៉ុក ដារ៉ា** អគ្គលេខាធិការរង គ.ជ.ប និងជាប្រធានដឹកនាំកិច្ចប្រជុំ បានមានប្រសាសន៍ថា ការលក់ ឬជួលម៉ោងឱ្យគណបក្សនយោបាយធ្វើការផ្សព្វផ្សាយអំពី



អគារ គ.ជ.ប៖ វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ៖ 012 959 666 / 092 105 556 / 012 855 018
NEC Building : St. Ratsaphea, Sangkat Tonle Basac, Khan Chamkar Mon, Phnom Penh, Kingdom of Cambodia អ៊ីម៉ែល៖ info@nec.gov.kh

គោលនយោបាយ ត្រូវផ្អែកតាមគោលការណ៍ស្មើភាព មានតម្លាភាព តម្លៃស្មើៗគ្នា និងតាមលំដាប់មុនក្រោយ ហើយមិនត្រូវលក់ ឬជួលម៉ោងផ្តាច់មុខឱ្យគណបក្សនយោបាយណាមួយឡើយ។

ឯកឧត្តមបានបន្ថែមទៀតថា ចំពោះការលក់ ឬជួលម៉ោងផ្សាយនេះ ស្ថានីយវិទ្យុ និងទូរទស្សន៍ត្រូវយកម៉ោងសរុបដែលចង់លក់ ឬជួល ចែកជាមួយនឹងចំនួនគណបក្សនយោបាយដែលចូលរួមក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ រួចជួល ឬលក់តែចំណែកម៉ោងដែលគណបក្សនយោបាយនីមួយៗត្រូវទទួលបានទៅឱ្យគណបក្សនយោបាយនីមួយៗនោះប៉ុណ្ណោះ។ ក្នុងករណីមានគណបក្សនយោបាយតិច ឬគណបក្សនយោបាយតែមួយទិញ ឬជួលម៉ោងផ្សាយស្ថានីយវិទ្យុ ឬទូរទស្សន៍ អាចលក់ ឬជួលម៉ោងផ្សាយឱ្យគណបក្សនយោបាយដែលមានលទ្ធភាពទិញ ឬជួលនោះនូវរយៈពេលយ៉ាងច្រើន ៣ ដងនៃរយៈពេលដែលគណបក្សនយោបាយនោះត្រូវទទួលបាន។

ដោយឡែកចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដែលមានបំណងរៀបចំកម្មវិធីសំណួរចម្លើយ ឬពិភាក្សាអំពីគោលនយោបាយរបស់គណបក្សនយោបាយដើម្បីផ្សព្វផ្សាយក្នុងអំឡុងពេលឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ អាចពិគ្រោះយោបល់ជាមួយគណៈកម្មការសម្របសម្រួល មុនចាប់ផ្តើមធ្វើកម្មវិធីនេះ ពាក់ព័ន្ធនឹងការងារបច្ចេកទេសមួយចំនួន ប្រធានបទ ឬសំណួរដែលត្រូវដាក់ជូនគណបក្សនយោបាយ និងការសម្របសម្រួលទីតាំងប្រជុំ វិធានការសន្តិសុខ សុវត្ថិភាព និងការការពារជំងឺឆ្លងរាលដាលកូវីដ-១៩។

ឯកឧត្តមបានជម្រាបជូនថា ការផ្សព្វផ្សាយកម្មវិធីសំណួរចម្លើយ ឬពិភាក្សាអំពីគោលនយោបាយរបស់គណបក្ស ពុំតម្រូវឱ្យមានលិខិតយល់ព្រមពី គ.ជ.ប ឡើយ ប៉ុន្តែអ្នកគ្រប់គ្រងកម្មវិធីនេះត្រូវតែមានការទទួលខុសត្រូវចំពោះមុខច្បាប់ ចំពោះការផ្សព្វផ្សាយកម្មវិធីរបស់ខ្លួន។ អ្នកគ្រប់គ្រងកម្មវិធី និងអ្នកសម្របសម្រួលកម្មវិធីសំណួរចម្លើយ ឬពិភាក្សា ត្រូវប្រកាន់ជំហរអព្យាក្រឹត។

ឯកឧត្តមប្រធានគណៈកម្មការសម្របសម្រួល បានស្នើឱ្យប្រព័ន្ធផ្សាយផ្សាយព័ត៌មានរដ្ឋ និងឯកជន សមាគម និងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ ចូលរួមធ្វើឱ្យការប្រព្រឹត្តទៅនៃការផ្សព្វផ្សាយគោលនយោបាយ និងកម្មវិធីនយោបាយរបស់គណបក្សនយោបាយ ក្នុងអំឡុងពេលឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ មានភាពត្រឹមត្រូវ ស្របតាមច្បាប់ បទបញ្ញា និងនីតិវិធីសម្រាប់ការបោះឆ្នោត ក្រមសីលធម៌ រួមនឹងគោលការណ៍កំណត់ដោយ គ.ជ.ប ដើម្បីឱ្យការបោះឆ្នោតខាងមុខនេះដំណើរការទៅដោយរលូន មានសណ្តាប់ធ្នាប់ សន្តិសុខ សុវត្ថិភាព ដោយសេរី ត្រឹមត្រូវ យុត្តិធម៌ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស។

កិច្ចប្រជុំផ្សព្វផ្សាយនេះ មានអ្នកចូលរួមសរុប ៣២ នាក់ ដែលជាតំណាងស្ថានីយវិទ្យុ និងទូរទស្សន៍ សរុបចំនួន ៨ អង្គភាព និងសមាគម និងអង្គការមិនមែនរដ្ឋាភិបាល សរុបចំនួន ៧ និងសមាជិកគណៈកម្មការសម្របសម្រួល។



អគារ គ.ជ.ប ៖ វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ ៖ 012 959 666 / 092 105 556 / 012 855 018
NEC Building : St. Ratsaphea, Sangkat Tonle Basac, Khan Chamkar Mon, Phnom Penh, Kingdom of Cambodia
អ៊ីមែល ៖ info@nec.gov.kh